ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

**សារជូនពរ**

**សូមគោរពជូន**

**សម្តេចអគ្គមហាពញាចក្រី កិត្តិព្រឹទ្ធបណ្ឌិត ហេង សំរិន ប្រធានរដ្ឋសភា**
**នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីចម្រើនជន្មាយុគម្រប់ ៨៧ ឈានចូល ៨៨ ឆ្នាំ**

**សម្តេចអគ្គមហាពញាចក្រី កិត្តិព្រឹទ្ធបណ្ឌិត ប្រធានរដ្ឋសភា ជាទីគោរពដ៏ខ្ពង់ខ្ពស់** !

ក្នុងឱកាសដ៏នក្ខត្តឫក្ស នៃពិធីចម្រើនជន្មាយុគម្រប់ ៨៧ ឈានចូល ៨៨ ឆ្នាំ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១នេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំនិងភរិយា សូមជូននូវសព្ទសាធុការពរជ័យសិរីមង្គលមហាប្រសើរ ជូនចំពោះ **សម្តេចអគ្គមហាពញាចក្រី កិត្តិព្រឹទ្ធបណ្ឌិត** សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួនខ្លាំងក្លា បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីបន្តដឹកនាំស្ថាប័នរដ្ឋសភាឱ្យកាន់តែមានការរីកចម្រើនថែមទៀត។

យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរពដ៏ស្មោះស្ម័គ្រ និងកោតសរសើរយ៉ាងក្រៃលែងនូវការដឹកនាំរបស់ **សម្តេចអគ្គមហាពញាចក្រី កិត្តិព្រឹទ្ធបណ្ឌិត** ជានិច្ចកាលតែងបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយ និងប្រាជ្ញាស្មារតី ជាមួយនឹងបទពិសោធន៍ដ៏ប៉ិនប្រសប់ប្រកបដោយគំរូវីរភាពដ៏អង់អាចមោះមុតសម្រេចបាននូវស្នាដៃ និងសមិទ្ធផលជាច្រើនគួរឱ្យស្ញប់ស្ញែងជាបន្តបន្ទាប់។ ក្រោមការដឹកនាំរបស់ **សម្តេច** បានជំរុញឱ្យស្ថាប័នរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលជាស្ថាប័នកំពូលរបស់ជាតិមានការរីកចម្រើនឥតឈប់ឈររួមចំណែកដល់ការលើកកម្ពស់នីតិរដ្ឋ ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស ស្របតាមបំណងប្រាថ្នាដែលប្រជាជនគ្រប់ៗរូបប្រាថ្នាចង់បាន។

ជាថ្មីម្តងទៀតក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូលក្នុងនាមខ្ញុំនិងភរិយា សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតាឆ្នាំថ្មី ទេវតារក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមប្រោះព្រំសព្ទសាធុការពរជ័យ សិរីមង្គល ជូនចំពោះ **សម្តេចអគ្គមហាពញាចក្រី កិត្តិព្រឹទ្ធបណ្ឌិត** និង **សម្តេចកម្ពុជបុត្រីសុទ្ធចរិយា** ព្រមទាំងបុត្រាបុត្រី ចៅប្រុសចៅស្រីជាទីស្រឡាញ់ សូមបានសម្រេចបាននូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម**សម្តេចអគ្គមហាពញាចក្រី កិត្តិព្រឹទ្ធបណ្ឌិត ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃសុក្រ ១០កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា **ទៀ បាញ់**